**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ៣០៤៦ PC.អក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពន្យារពេលបើកឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ក្នុងគម្រោងការងារសំណង់ ចំនួន ០២ គម្រោង

**យោង ៖** -ភាពចាំបាច់របស់អគ្គិសនីកម្ពុជា ។

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនផ្គត់ផ្គង់/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទិញឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ក្នុងគម្រោងដូចខាងក្រោមឲ្យបានជ្រាបថា៖

១. ការងារសាងសង់នៅស្នាក់ការព្រែកប្រសព្វ ជូន អគ្គិសនីក្រចេះ (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១) ។

២. ការងារលាបថ្នាំជញ្ជាំងអគារឃ្លាំងផ្នែកខាងក្រៅ ទំហំ (24.5m x 15.5m) កម្ពស់ 12m នៅអគ្គិសនីកំពង់ចាម, សាងសង់របងព័ទ្ធជុំវិញ ប្រវែង 438.20m និងចាក់បេតុងដែកផ្លូវ ទំហំ 1,316m² កម្រាស់ 0.15m នៅទីតាំងដីឃ្លាំងថ្មី (ជិតភ្នំប្រុសភ្នំស្រី) ជូន អគ្គិសនីកំពង់ចាម (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១) ។

ដោយគម្រោងនេះមានទំហំការងារ ក៏ដូចជាគំនូសប្លង់មួយចំនួនត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ ។ ដូចនេះ អគ្គិសនីកម្ពុជា សូមពន្យារពេលបើកឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈក្នុងគម្រោងខាងលើនេះ និងរៀបចំជូនដំណឹងសារជាថ្មីវិញនាពេលខាងមុខ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបណ្តាក្រុមហ៊ុនផ្គត់ផ្គង់/សហគ្រាស ទាំងអស់ជ្រាបជាព័ត៌មាន ។

ថ្ងៃអង្គារ ១៣កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០២១
ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

**ហាច់ ទូច**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-នាយកដ្ឋានរដ្ឋបាល
-អគ្គិសនីក្រចេះ
-អគ្គិសនីកំពង់ចាម
-ឯកសារ-កាលប្បវត្តិ